ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៧/២១ - ឌីនហាន អេនធើប្រាយ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **គល់ វិឡូនា**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៧ ៤៤ ០៦ ៧៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក QI Bing | អ្នកគ្រប់គ្រង |
| ២- លោក លៀង ដាលីន | រដ្ឋបាល |
| ៣- លោក អ៊ុ អៀង | អ្នកបកប្រែ |
| ៤- លោក នៅ ហ៊ួត | តំណាងកម្មករនិយោជិត |
| ៥- លោក សួន ពៅ | តំណាងកម្មករនិយោជិត |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៦៩ ៨៨ ២២ ៨២ ០៨៧ ៧៧៧ ៨១៩ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | ប្រធានការិយាល័យច្បាប់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោក សាអ៊ី រិទ្ធ | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- លោក ឡុង សក្កដា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ឌីនហាន អេនជើ-ប្រាយ ខូអិលធីឌី |
| ៤- លោក មុយ រឿន | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឌីនហាន អេនជើ-ប្រាយ ខូអិលធីឌី |
| ៥- លោកស្រី ឈឹម សិរីពុំ | លេខាសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឌីនហាន អេនជើ-ប្រាយ ខូអិលធីឌី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីតំណាងកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតដែលឆ្លងជំងឺកូវីដ១៩ ដោយចាត់ចូលជាច្បាប់ឈឺតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនដោយរាប់ទាំងថ្ងៃធ្វើចត្តាឡីស័កផងដែរ។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថាក្រុមហ៊ុននឹងផ្តល់ជូនប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗចំនួន៥០% ជូនកម្មករនិយោជិតដែលឆ្លងកូវីដ១៩។

២- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់ប្រាក់វិភាគទាន របស់សកម្មជនសហជីពដែលមិនព្រមលាលែងពីសហជីព។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបានបញ្ជាក់ថានឹងលើកយកបញ្ហានេះទៅពិភាក្សាជាមួយកម្មករនិយោជិតផ្ទាល់ផ្អែកតាមនីតិវិធីច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូក ទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី លេខ ៦៦៥ ក.ប/អក/វក ចុះថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣៦៣ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ របស់តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ៥ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៣ចំណុច លើការទាមទារចំនួន ៥ចំណុច។ ចំណុចមិនសះជាចំនួន ២ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី លេខ ៦៦៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) និងបន្ទប់សវនាការ ត្រូវបានបែងចែករវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ នៅក្នុងសវនាការ ភាគីទាំងពីរមិនមានការជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ហើយភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទទី២ ចេញពីសំណុំរឿងនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុច គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី ចុះទិដ្ឋាការលេខ ០៤ ក.ប/អក/អធ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ចេញដោយនាយកដ្ឋានអធិការកិច្ចការងារ។

THE ARBITRATION COUNCIL

២- លក្ខន្តិកៈក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី បានតម្កល់ទុកលេខ ២៤៨៦/១២ ពណ.ចបព ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២១។

៤- សេចក្តីណែនាំលេខ ០៤១/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីវិធានការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅរោងចក្រ ឌីន ហាន អេនធើប្រាយ។

៥- សេចក្តីណែនាំលេខ ០២២/២១ ក.ប/ស.ជ.ណ.ន.ខ.ល ចុះថ្ងៃសៅរ៍ ១២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការចូលធ្វើការឡើងវិញ និងការបើកប្រាក់ឈ្នួលរបស់បងប្អូនកម្មករនិយោជិត នៅតាមរោងចក្រ សហគ្រាស ដែលបើកដំណើរការឡើងវិញក្រោយការបញ្ចប់វិធានការបិទខ្ទប់។

៦- សេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃចន្ទ ៨កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការបើកប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

៧- លិខិតចុះថ្ងៃអង្គារ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់តំណាងនាយកក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាលស្តីពីការផ្តល់ប្រាក់ឈ្នួលចំពោះអ្នកកើតកូវីដ-១៩។

៨- លិខិតចុះថ្ងៃព្រហស្បតិ៍ ១៥កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងនាយកក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ គោរពជូន ក្រុមប្រឹក្សាអាជ្ញា-កណ្តាល ស្តីពីការផ្តល់ប្រាក់ឈ្នួលចំពោះអ្នកកើតកូវីដ-១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- ឯកសារសំណួរចម្លើយ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រាក់ឈ្នួល ឬការប៉ះប៉ូវពី ប.ស.ស សម្រាប់កម្មករនិយោជិតដែលមានជំងឺកូវីដ១៩។

២- តារាងកំណត់ហេតុ ការឈប់សម្រាកប្រចាំឆ្នាំ និងការឈប់សម្រាកពិសេស ចំនួន ៧ថ្ងៃ ប្រចាំឆ្នាំ ២០២១។

៣- លិខិតសុំច្បាប់ប្រចាំឆ្នាំ២០២១ របស់ឈ្មោះ ស៊ាន ស៊ីណា ចេញដោយក្រុមហ៊ុន ឌីនហាន អេនធើ-ប្រាយ ខូអិលធីឌី។

៤- កិច្ចសន្យា ស្តីពីការបន្តអនុវត្តវិធានការសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោយការចាក់វ៉ាក់សាំងជាសះស្បើយជំងឺកូវីដ-១៩ របស់កម្មករនិយោជិតចំនួន ៤ច្បាប់ ស្មើនឹង ៤សន្លឹក។

៥- លិខិតអនុញ្ញាតចេញពីមន្ទីរពេទ្យ ចេញដោយមណ្ឌលព្យាបាលកូវីដ-១៩ ចំពោះកម្មករនិយោជិត ដែលបានទទួលការព្យាបាលជំងឺកូវីដ-១៩ ចំនួន ១៣ច្បាប់ ស្មើនឹង ១៣សន្លឹក។

៦- លិខិតបញ្ជាក់ ស្តីពីទីលំនៅ និងការព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ ចេញដោយអាជ្ញាធររដ្ឋបាលសង្កាត់ ចំពោះកម្មករនិយោជិត ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធចំនួន ១៣ច្បាប់។

៧- លិខិតប្រគល់-ទទួលឯកសារទាមទារតាវកាលិកផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ចេញដោយបេឡាជាតិរបបសន្តិសុខសង្គម ភ្ជាប់ជាមួយឯកសារពាក់ព័ន្ធចំនួន ១៣ច្បាប់។

៨- លក្ខន្តិកៈ នៃសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី ចុះបញ្ជីលេខ ១១២១៨០៣២០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ ដោយនាយកដ្ឋានវិវាទការងារ។

៩- លិខិតលេខ ០២៦/១៨ ក.ប/វក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

១០-វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករ នៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី លេខ ០៣៨/១៨ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី លេខ ៦៦៥ ក.ប/អក/វក ចុះថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឌីនហាន អេនជើប្រាយ ខូអិលធីឌី លេខ ០០៥/២១ កប/អក/វក/កវក៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៥៧ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៥៨ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី គឺជាក្រុមហ៊ុនដែលមានសកម្មភាពកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ២៧២៨នាក់ *(យោងតាមរបាយការណ៍លេខ ៦៦៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី)*។
- សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឌីនហាន អេនធើប្រាយ ខូអិលធីឌី ទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាសហជីព ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៣៨/១៨ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ និងមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព លេខ ០២៦/១៨ ក.ប/វក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ ដែលមានឈ្មោះ ១. លោក ឡុង សក្កដា ជាប្រធាន, ២. លោក មុយ រឿន ជាអនុប្រធាន និង៣. លោកស្រី ឈឹម សិរីពុំ ជាលេខាធិការិនី។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៥/២១ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ដែលមានកម្មករនិយោជិតចំនួន ៣នាក់ រួមមាន ៖ ១. ឡុង កក្កដា, ២. មុយ រឿន និង ៣. ឈឹម សិរីពុំ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកគិតប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលឆ្លងជំងឺកូវីដ-១៩ ដោយចាត់ចូលជាការឈប់សម្រាកឈឺ តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដោយរាប់ទាំងថ្ងៃធ្វើចត្តាឡីស័កផងដែរ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយបន្ថែមទៀត, ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - នៅក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០២១ មានកម្មករនិយោជិតបានឆ្លងជំងឺកូវីដ-១៩ ហើយក្នុងអំឡុងពេលព្យាបាល និងអំឡុងពេលធ្វើចត្តាឡីស័ក គឺកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលចំនួន ១០០ភាគរយ។
    - ចំណែកនៅក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២១ មានកម្មករនិយោជិតច្រើនបានឆ្លងជំងឺកូវីដ-១៩ និយោជកក៏បានផ្អាកសកម្មភាពការងារនៅក្នុងក្រុមហ៊ុនជាបណ្តោះអាសន្ន ដោយនិយោជកបានផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ ជូនកម្មករនិយោជិតដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១។
    - និយោជកបើកដំណើរការក្រុមហ៊ុនវិញ ចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - នៅក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០២១ មានកម្មករនិយោជិតបានឆ្លងជំងឺកូវីដ-១៩ ចំនួន ៣២ នាក់។ នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២១ មានកម្មករនិយោជិតបានឆ្លងជំងឺកូវីដ-១៩ ចំនួន ៧០០នាក់ ហេតុនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន

១០០ភាគរយ ជូនកម្មករនិយោជិតដែលបានឆ្លងជំងឺកូវីដ-១៩ ចំនួន ៧០០នាក់ ឱ្យដូចកម្មករនិយោជិតចំនួន ៣២នាក់ ដែលបានឆ្លងកូវីដ-១៩។

- និយោជក បានផ្អាកសកម្មភាពការងារនៅក្នុងក្រុមហ៊ុនជាបណ្ដោះអាសន្ន ចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ដោយមានសេចក្ដីណែនាំឱ្យផ្អាកសកម្មភាពការងារពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប៉ុន្តែសេចក្ដីណែនាំនេះមិនបានកំណត់ពេលវេលាជាក់លាក់នៃការអនុញ្ញាតឱ្យបើកដំណើរការក្រុមហ៊ុនឡើងវិញនោះទេ។
- យោងតាមចំណុចទី៦ ប្រការ ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន បញ្ជាក់ថា កម្មករនិយោជិតត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១០០ភាគរយ នៅពេលដែលកម្មករនិយោជិតសម្រាកព្យាបាលជំងឺ ព្រោះការសម្រាកព្យាបាលជំងឺកូវីដ-១៩ ត្រូវចាត់ទុកជាការឈប់សម្រាកដោយមានជំងឺ ហើយប្រការខាងលើបានកំណត់ឱ្យកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលចំនួន ១០០ភាគរយ នៅពេលដែលឈប់សម្រាកដោយមានជំងឺផងដែរ។
- ភាគីកម្មករនិយោជិតយល់ឃើញថា ជំងឺកូវីដ-១៩ គឺជាជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយកម្មករនិយោជិតមានជំងឺ ឬមិនមានជំងឺ មានតែគ្រូពេទ្យប៉ុណ្ណោះដែលអាចបញ្ជាក់បាន ហើយកម្មករនិយោជិតចំនួន ៧០០នាក់ គឺមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ។
- ជំងឺកូវីដ-១៩ មិនមែនជាករណីប្រធានសក្តិនោះទេ ពីព្រោះករណីនេះ គឺយើងអាចដឹងទុកមុន និងអាចការពារបានដោយគោរពតាមវិធានការការពារ។ ករណីប្រធានសក្តិមិនអាចដឹងមុនបាននោះទេ ដូចជាករណីគ្រោះទឹកជំនន់ ឬករណីគ្រោះធម្មជាតិ។ ករណីជំងឺកូវីដ-១៩ នេះ និយោជកមានកាតព្វកិច្ចអនុវត្តស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនចំពោះ កម្មករនិយោជិតដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក។
- នៅក្នុងបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត និយោជកផ្ដល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយប៉ុណ្ណោះ ដល់កម្មករនិយោជិត ហើយនិយោជកមិនបានផ្ដល់ជូនប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារជូនកម្មករនិយោជិតនោះទេ។

- ភាគីនិយោជកមិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - នៅខែកុម្ភៈ និងខែមីនា ឆ្នាំ២០២១ មានកម្មករនិយោជិតចំនួនតិចដែលបានឆ្លងជំងឺកូវីដ-១៩ ហើយនិយោជកមានលទ្ធភាព ទើបនិយោជកផ្ដល់ជូនប្រាក់ឈ្នួលចំនួន ១០០ភាគរយ ជូនកម្មករនិយោជិត។
  - នៅខែមេសា និងខែឧសភា ឆ្នាំ២០២១ មានកម្មករនិយោជិតស្ទើរតែពាក់កណ្ដាលនៃកម្មករនិយោជិតសរុបបានឆ្លងជំងឺកូវីដ-១៩ និយោជកក៏បានផ្អាកសកម្មភាពការងារទាំងស្រុង បណ្ដាលឱ្យមានការខាតបង់ច្រើន ហេតុនេះ និយោជកមិនមានលទ្ធភាពផ្ដល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតនោះទេ។
  - និយោជកអនុវត្តតាមសេចក្ដីណែនាំរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានផ្អាកសកម្មភាពការងារនៅក្នុងក្រុមហ៊ុនជាបណ្ដោះអាសន្ន ចាប់ពីដើមខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១។
  - និយោជកអនុវត្តស្របតាមសេចក្ដីណែនាំរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លេខ ០៤៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ នៅក្នុងអំឡុងពេលផ្អាកសកម្មភាពការងារនៅក្នុង

ក្រុមហ៊ុន និយោជកបានផ្តល់ប្រាក់ឈ្នួលសុទ្ធសាធជូនកម្មករនិយោជិតចំនួន ៥០ភាគរយ, ប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ និងប្រាក់រង្វាន់ធ្វើការទៀងទាត់តាមសមាមាត្រ ផ្អែកលើចំនួនថ្ងៃដែលកម្មករនិយោជិតបានមកធ្វើការ។

- ០ ជំងឺកូវីដ-១៩ មិនមែនជាជំងឺធម្មតានោះទេ ពីព្រោះជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងជាសកលដែលលទ្ធភាពនៃការទទួលខុសត្រូវរបស់និយោជក គឺមានកម្រិត។ ហេតុនេះ និយោជកមិនអាចយកចំណុចទី៦ ប្រការ ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមកអនុវត្តបាននោះទេ។

- យោងតាមឯកសារកស្តុតាងរបស់ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញ ៖
  - ០ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ បានកំណត់ថា ៖ *"ប្រការ ៤ ...ការឈប់សម្រាកដោយជម្ងឺ: ចំពោះអ្នកមានជម្ងឺ ដែលមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញក្នុងរយៈពេល ១ខែ ដំបូង។ នៅខែទី២ និងខែទី៣ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលតែ ៦០%។ ចាប់ពីខែទី៤ ដល់ខែទី៦ ក្រុមហ៊ុនមិនផ្តល់ប្រាក់ឈ្នួលឱ្យទេ តែរក្សាក្របខ័ណ្ឌដដែល។ បើឈប់សម្រាកលើសពី ៦ខែ ក្រុមហ៊ុន នឹងពិនិត្យពិចារណា បញ្ឈប់ពីការងារ ដោយអនុវត្តតាមច្បាប់ស្តីពីការងារ។"*
  - ០ សេចក្តីណែនាំលេខ ០៤១/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ ស្តីពីវិធានការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅរោងចក្រ ឌីន ហាន អេនធើប្រាយ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ថា ៖ *"ដើម្បីគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩...នៅរោងចក្រ ឌីន ហាន អេនធើប្រាយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមធ្វើការណែនាំ ដូចខាងក្រោម៖*

    ***១. ចំពោះម្ចាស់ ឬនាយករោងចក្រ ត្រូវ៖***
    - *ផ្អាកដំណើរការរោងចក្របណ្តោះអាសន្ន ចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១។*
    - *...*
    - *ផ្តល់ការសហការសម្របសម្រួលដល់កម្មករនិយោជិត ដែលបានកំណត់ឱ្យធ្វើចត្តាឡីស័ក នៅតាមផ្ទះចំនួន ១៤ថ្ងៃ ដោយត្រូវផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៧ថ្ងៃ...។*
    - *....។"*

- យោងតាមឯកសារកស្តុតាងរបស់ភាគីកម្មករនិយោជិត ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ អំពីការបកស្រាយសំណួរទី៤០ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ថា ៖ *"...ក្នុងអំឡុងពេលព្យាបាល (រួមទាំងពេលធ្វើចត្តាឡីស័ក ក្រោយពេលជាសះស្បើយ) កម្មករនិយោជិតទទួលបាន ៖ ប្រាក់ឈ្នួល ដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រសហគ្រាស ចំពោះការឈប់សម្រាកដោយជំងឺ។..."*។
- យោងតាមឯកសារកស្តុងតាមរបស់ភាគីនិយោជក ដាក់ជូនដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០២១ បញ្ជាក់ថា ៖ *"...ក្រសួងការងារ បកស្រាយសំណួរទី៤០: ប្រសិនបើ ករណីនេះជាឯកសារផ្លូវការ ហើយគ្រប់បណ្តាក្រុមហ៊ុនត្រូវបានអនុវត្តន៍តាម ដូចនេះក្រសួងគួរចេញលិខិតផ្លូវការអោយបានច្បាស់លាស់"*។

THE ARBITRATION COUNCIL

- ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សំណួរចម្លើយទាក់ទងនឹងការព្យាបាលជំងឺកូវីដ-១៩នេះ មិនមែនជាលិខិតបទដ្ឋានគតិយុត្តនោះទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ បន្ថែមទៀត, ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និង ពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើអំឡុងពេលដែលកម្មករនិយោជិតសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ អាចអនុវត្តចំពោះការឈប់សម្រាកដោយមានជំងឺ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនដែរ ឬទេ?

ចំណុចទី៣ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"កិច្ចសន្យាការងារ ត្រូវព្យួរដោយមូលហេតុដូចខាងក្រោម ៖ ...*

*៣-អវត្តមាននៃកម្មករនិយោជិតក្នុងករណីមានជម្ងឺ ដែលមានគ្រូពេទ្យផ្លូវការបានបញ្ជាក់ត្រឹមត្រូវ។ ចិរវេលាអវត្តមាននោះត្រូវមានកំណត់ត្រឹមប្រាំមួយខែ ប៉ុន្តែអាចពន្យារហូតដល់មានអ្នកជំនួស ។"*

ចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ការព្យួរកិច្ចសន្យាការងារ នាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត។...។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៧១/១៣-បូវយើរ ហ្គាមេន ហ្វេកជើរី ហេតុផលនៃចំណុចវិវាទទី៦ បានបកស្រាយ ចំណុចទី៣ មាត្រា ៧១ និងចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើថា ៖ *"ការឈប់ឈឺរបស់កម្មករនិយោជិត ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវ គឺជាការព្យួរកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត។ ដូច្នេះ នៅពេលដែលកម្មករនិយោជិតអវត្តមាន ដោយមានជម្ងឺនាំឱ្យកិច្ចសន្យាការងារត្រូវបានព្យួរ ហើយកម្មករនិយោជិតក៏មិនតម្រូវឱ្យធ្វើការឱ្យនិយោជកដែរ។ រីឯនិយោជកក៏មិនតម្រូវឱ្យផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតដែរ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០១៦/១៥ ក្រុមហ៊ុន សានដុង ហ្វីសេវូដ (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៤, លេខ ២០៤/១៦-វ៉ូណាមមី (ខេមបូឌា) ហ្គាមេន ហេតុផលនៃចំណុចវិវាទ)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងតាមបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ៧០០នាក់ បាន ឈប់សម្រាកព្យាបាលជំងឺកូវីដ-១៩ និងធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ដោយការឈប់សម្រាកនេះ គឺជាការព្យួរកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ដោយកម្មករនិយោជិតមិនតម្រូវឱ្យធ្វើការឱ្យនិយោជក រីឯនិយោជកក៏មិនតម្រូវឱ្យផ្តល់ប្រាក់ឈ្នួលឱ្យ

កម្មករនិយោជិតដែរ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ស្របតាមចំណុចទី៣ មាត្រា ៧១ និងចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ។

ក្នុងករណីនេះ ភាគីនិយោជកបានលើកឡើងថា និយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ , ប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ, និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជាសមាមាត្រតាមចំនួនថ្ងៃដែលកម្មករនិយោជិតបានមកធ្វើការ ជូនកម្មករនិយោជិតឈប់សម្រាកព្យាបាលជំងឺកូវីដ-១៩ និងធ្វើចត្តាឡីស័ក។ តែយ៉ាងណាមិញ ភាគីកម្មករនិយោជិតបានលើកឡើងថា និយោជកមិនបានផ្តល់ជូនប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារជូនកម្មករនិយោជិតនោះទេ ហេតុនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ បន្ថែមទៀត, ជាមួយប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលបានសម្រាកព្យាបាលជំងឺកូវីដ-១៩ និងបានធ្វើចត្តាឡីស័កស្របតាមប្រការ ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

យោងតាមប្រការ ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ ២០១៣ បានកំណត់ថា ៖ *"...ការឈប់សម្រាកដោយជម្ងឺ: ចំពោះអ្នកមានជម្ងឺ ដែលមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញក្នុងរយៈពេល ១ខែ ដំបូង។ នៅខែទី២ និងខែទី៣ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលតែ ៦០%។ ចាប់ពីខែទី៤ ដល់ខែទី៦ ក្រុមហ៊ុនមិនផ្តល់ប្រាក់ឈ្នួលឱ្យទេ តែរក្សាក្របខ័ណ្ឌដដែល។ បើឈប់សម្រាកលើសពី ៦ខែ ក្រុមហ៊ុន នឹងពិនិត្យ ពិចារណា បញ្ឈប់ពីការងារដោយអនុវត្តតាមច្បាប់ស្តីពីការងារ។"*

យោងតាមបទបញ្ជាផ្ទៃក្នុងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនបានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត នៅពេលកម្មករនិយោជិតឈប់សម្រាកដោយមានជំងឺដែលមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ។ ដោយឡែក ភាគីនិយោជកបានលើកឡើងថា ជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងជាសកលដែលលទ្ធភាពនៃការទទួលខុសត្រូវរបស់និយោជក គឺមានកម្រិត ហេតុនេះ និយោជកមិនអាចយកបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមកអនុវត្តបាននោះទេ។ ជាងនេះទៀត នៅពេលដែលកម្មករនិយោជិតសម្រាកព្យាបាលជំងឺកូវីដ-១៩ និងធ្វើចត្តាឡីស័ក គឺក្រុមហ៊ុនត្រូវបានផ្អាកសកម្មភាពការងារទាំងស្រុង ស្របតាមសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយក្រុមហ៊ុនមិនមានប្រាក់ចំណូលនោះទេ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងរាលដាលថ្មី ដែលមានលក្ខណៈឆ្លងរាលដាលជាសកល។ នៅក្នុងបរិបទនេះ គឺមានច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ព្រមទាំងមានវិធានការសុខាភិបាលចាំបាច់នានា ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗ ដើម្បីគ្រប់គ្រង និងបង្ការការឆ្លងរាលដាលនៃជំងឺនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងបរិបទជំងឺកូវីដ-១៩ ដែលជាជំងឺឆ្លងរាលដាលថ្មីជាសកល និយោជកត្រូវគោរពតាមវិធានការសុខាភិបាលនានាដែលបានកំណត់។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានផ្អាកសកម្មភាពការងារនៅក្នុងក្រុមហ៊ុនជាបណ្តោះអាសន្ន ស្របតាមសេចក្តីណែនាំលេខ ០៤១/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ ស្តីពីវិធានការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅរោងចក្រ ឌីន ហាន អេនធើប្រាយ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់ពីកាតព្វកិច្ចរបស់និយោជកផ្អាកសកម្មភាពការងារនៅក្នុងក្រុមហ៊ុនជាបណ្តោះអាសន្ន ចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១

និងណែនាំឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធ ជូនកម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័កនៅតាមផ្ទះចំនួន ៧ថ្ងៃ។

បន្ថែមលើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា រាជរដ្ឋាភិបាលក៏បានចេញសេចក្តីសម្រេចបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាបន្តបន្ទាប់ រួមមាន ៖ សេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ (បិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១) និងសេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ (បិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល សម្រាប់រយៈពេល ៧ថ្ងៃ បន្តទៀត រហូតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១) ដែលបុគ្គលគ្រប់រូបត្រូវបានហាមឃាត់ក្នុងការធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប្រសិនបើគ្មានការចាំបាច់។ បន្ទាប់ពីនេះទៀត រដ្ឋបាលរាជធានីភ្នំពេញ ក៏បានដាក់ចេញសេចក្តីសម្រេចលេខ ១០០/២១ សសរ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ ស្តីពីការដាក់ចេញវិធានការរដ្ឋបាល សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយបែងចែកជា "តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង" ចាប់ពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ក្នុងនោះដែរក៏មាន ខណ្ឌមានជ័យ ជាតំបន់ក្រហម ដោយមានសង្កាត់ស្ទឹងមានជ័យទី១ ផ្នែកខ្លះនៃភូមិថ្មី។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ មានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ពោលគឺត្រូវស្ថិតនៅក្នុងតំបន់ក្រហម ដែលត្រូវបានបិទខ្ទប់ និងត្រូវបានហាមឃាត់នូវសកម្មភាពកិច្ចការផ្សេងៗ។

យោងតាមសេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការបើកប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ថា ៖ *"យោងតាមច្បាប់ស្តីពីការងារ ការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដោយសារការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននូវភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល នាំឱ្យមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។ ដើម្បីជានាផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិតនៅក្នុងអំឡុងពេលបិទខ្ទប់នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំ... ដូចខាងក្រោម៖*

*...*

*២. ត្រូវបើកប្រាក់ឈ្នួលដើមខែមេសា (ប្រាក់ឈ្នួលសម្រាប់ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២១...ប្រសិនបើមិនទាន់បានបើកផ្តល់នាពេលកន្លងមក។...*

*៣. ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់កម្មករនិយោជិតរបស់ខ្លួនទៅតាមលទ្ធភាព ដោយផ្អែកលើស្មារតីមនុស្សធម៌ សាមគ្គីភាព និងទំនួលខុសត្រូវសង្គមនៅក្នុងគ្រាលំបាករួមនេះ។...*

*..."។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០១៥/២១-គួ តាយ ហ័រ សេង ស៊ីន ហ្គេង ជីង ហេតុផលនៃចំណុចវិវាទទី២ បានបកស្រាយសេចក្តីណែនាំ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ខាងលើថា ៖ *"សេចក្តីណែនាំ ០៤៣/២១ បានកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់*

THE ARBITRATION COUNCIL

*ប្រាក់ឈ្នួលសម្រាប់ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ប៉ុន្តែមិនបានកំណត់កាតព្វកិច្ចឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតសម្រាប់ថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ទេ ដោយគ្រាន់តែណែនាំឱ្យនិយោជកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់កម្មករនិយោជិតតាមលទ្ធភាព ដោយផ្អែកលើស្មារតីមនុស្សធម៌ សាមគ្គីភាព និងទំនួលខុសត្រូវសង្គមក្នុងគ្រាលំបាក ពីព្រោះសេចក្តីណែនាំនេះបានបញ្ជាក់ថា ការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដោយសារការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននៅភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នាំឱ្យមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងតាមបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានផ្អាកសកម្មភាពការងារបណ្តោះអាសន្ន ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ដើម្បីគោរពតាមវិធានការណែនាំផ្សេងៗ របស់អាជ្ញាធរមានសមត្ថកិច្ច និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងគ្រឹះស្ថាន ឬសហគ្រាស។ ហេតុនេះ ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៧០០ នាក់ ដែលត្រូវសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ត្រូវបានព្យួរស្របតាមចំណុចទី៣ មាត្រា ៧១ និងចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ។ ដូចនេះ យោងតាមសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលក្នុងការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងយោងតាមសេចក្តីណែនាំលេខ ០៤៣/២១ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១ ខាងលើ គឺមិនបានកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័កនោះទេ។ ជាមួយគ្នានេះ និយោជកក៏បានផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ផងដែរ។

ហេតុនេះ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អំឡុងពេលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ សម្រាប់កម្មករនិយោជិតចំនួន ៧០០នាក់ មិនអាចអនុវត្តចំពោះការឈប់សម្រាកដោយមានជំងឺ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនបាននោះទេ ដោយហេតុថា និយោជកមានកាតព្វកិច្ចត្រូវអនុវត្តស្របតាមវិធានការសុខាភិបាលនានា និងវិធានការណែនាំផ្សេងៗ របស់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល, ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ នោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ បន្ថែមទៀត, ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

THE ARBITRATION COUNCIL

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០ភាគរយ បន្ថែមទៀត, ប្រាក់រង្វាន់ធ្វើការទៀងទាត់ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ១០០ភាគរយ ជូនកម្មករនិយោជិតចំនួន ៧០០នាក់ ដែលសម្រាកព្យាបាលជំងឺកូវីដ-១៩ និងពេលធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **គល់ ទន្សានា**

ហត្ថលេខា ៖ ------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL